# អ្នកស្រី ស៊ុយហ្សាន ការប៉ឺឡែស និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ដោយ ឃីង ហុកឌី
អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រ ក្រុងប៉ារីស
សិក្សាបនធារីនៅវិទ្យាស្ថានជាតិនៃភាសានិងអារ្យធម៌នៃចុងបូព៌ាប្រទេស ក្រុងប៉ារីស

## ជីវប្រវត្តិ (ប៉ារីស, គ.ស. ១៨៩០-១៩៦៨)[១]

**ស៊ុយហ្សាន ការប៉ឺឡែស** កើតនៅក្រុងប៉ារីស ប្រទេសបារាំង នាឆ្នាំ ១៨៩០ ។ ពេលអ្នកស្រីរៀនចប់មធ្យមសិក្សាហើយ បានចូលរៀនតណ្ណាវិជ្ជានៅ «សាលាអនុវត្តសិក្សាខ្ពស់» ជាមួយសាស្ត្រាចារ្យ ស៊ីលវ៉ាំង ឡេវី, អាលហ្វ្រេត ហ្វ៊ូស្សេ និង លូី ហ៊ីណូត៍ នៅរវាងសង្គ្រាមលោកលើកទី ១ គឺ នៅក្នុងឆ្នាំ ១៩១៤-១៨ ។ អ្នកស្រីបានទទួលសញ្ញាប័ត្រសាលានេះ នាឆ្នាំ ១៩១៩ ហើយបានសរសេរបោះពុម្ពផ្សាយជាដំបូងនូវអត្ថបទសិក្សាស្រាវជ្រាវ ១ ក្នុង [**សារព័ត៌មានអាស៊ី**] (Journal asiatique) ស្ដីពី «លោកេស្វរសតកៈ ឬ ១០០ បទជាកិត្តិយសដល់អាទិទេពពិភពលោក ដោយវជ្រទត្ត»[២] [៣] ។ អ្នកស្រី ការប៉ឺឡែស បានទទួលសញ្ញាប័ត្រ «សាលាភាសាបូព៌ា» ផ្នែកភាសាសៀម នៅឆ្នាំ ១៩២១[៤] ។

នៅឆ្នាំ ១៩២២ អ្នកស្រី ការប៉ឺឡែស បានចូលធ្វើការជាសមាជិកសាលាបារាំងចុងបូព៌ា[៥] ហើយធ្វើដំណើរដល់ក្រុងហាណូយនៅថ្ងៃទី ១ មករា ១៩២៣ ។ អ្នកស្រីបានចាប់ផ្ដើមសិក្សាអត្ថបទភាសាបាលីដែលបានបោះពុម្ពផ្សាយមកហើយនៅស្រីលង្កា ដោយយកមកប្រៀបធៀបនឹងគម្ពីរសរសេរដោយដៃនៅប្រទេសកម្ពុជា ។ ចាប់ពីខែឧសភា អ្នកស្រីបានទៅបំពេញបេសកកម្មនៅក្រុងបាងកក ដើម្បីស្រាវជ្រាវរកគម្ពីរដែលមានលក្ខណៈដូចគ្នា ហើយឆ្លៀតពេលនោះខំសិក្សាភាសាសៀមដែលចេះដឹងមកហើយ ឲ្យកាន់តែមានសុក្រឹតភាពថែមទៀត[៦] ។ ក្នុងឆ្នាំដដែលនេះ ពេលដែលត្រឡប់ពីប្រទេសសៀមវិញ អ្នកស្រីបានចុះស្នាក់នៅអង្គរ ។ នៅឆ្នាំ ១៩២៤ អ្នកស្រីបានធ្វើបេសកកម្មម្ដងទៀតនៅអង្គរ ហើយអ្នកស្រីបានត្រូវលោក ម៉ាកស្ហាល ជាបុរាណវិទូចំណាន ទទួលឲ្យទស្សនាប្រាសាទនានា ។ នៅក្នុងឆ្នាំដដែលនេះ អ្នកស្រីបានប្រែជាភាសាបារាំងបោះពុម្ពក្នុង [**ទស្សនាវដ្ដីឥណ្ឌូចិន**] នូវ «រឿងព្រេងបាលីប្រាំមួយចេញពី **ធម្មបទដ្ឋកថា**»[៧] ។

នៅខែធ្នូ ឆ្នាំ ១៩៣៦ អ្នកស្រី ការប៉ឺឡែស មានមុខនាទី ២ រួមគ្នា គឺ អ្នកស្រីបានត្រឡប់ទៅជាសមាជិកអចិន្ត្រៃយ៍សាលាបារាំងចុងបូព៌ា ហើយនិងមានមុខនាទីជាអគ្គលេខាធិការជាប់កិច្ចសន្យានៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យកម្ពុជា[៨] ។ នៅពេលសង្គ្រាមលោកលើកទី ២ ជាពិសេសគឺនៅឆ្នាំ ១៩៤១ ក្រោមរដ្ឋាភិបាលវីស៊ី អាជ្ញាធរបារាំងសែសនៅឥណ្ឌូចិន បានព្យួរតំណែងអ្នកស្រី ដោយម្យ៉ាង អ្នកស្រីមានដើមកំណើតជាជនជាតិស៊ីហ្វ[៩] ម្យ៉ាងទៀត អ្នកស្រីបានបម្រើផលប្រយោជន៍ខ្មែរជាជាងផលប្រយោជន៍រដ្ឋាភិបាលបារាំងសែស ព្រោះពុទ្ធសាសនបណ្ឌិត្យជាជម្រកនៃជនដែលប្រឆាំងនឹងអាណានិគមបារាំងសែស ។ អាជ្ញាធរបារាំងសែសបានតែងតាំងលោក ពីយែរ ឌុយប៉ុង ជំនួសអ្នក

*ស្រី[១០] ។ តែអ្នកស្រីបានត្រឡប់មកធ្វើការឡើងវិញនៅពេលចប់សង្គ្រាមលោកលើកទី ២ នេះ ។*

*អ្នកស្រី ការប៉ឺឡែស មានឥទ្ធិពលយ៉ាងខ្លាំងក្លាលើព្រះភិក្ខុ ជួន-ណាត[១១] និងព្រះភិក្ខុ ហួត-តាត[១២] ជាពិសេសលើការអប់រំខាងចំណេះដឹងជាទូទៅនៃព្រះពុទ្ធសាសនានិងព្រះធម៌ ហើយដល់ពេលក្រោយមក ព្រះភិក្ខុទាំង ២ អង្គនេះបានទទួលតំណែងបន្តបន្ទាប់ជា «សម្តេចព្រះសង្ឃរាជគណៈមហានិកាយ» ពោលគឺ រវាងឆ្នាំ ១៩៥០ រហូតដល់ឆ្នាំ ១៩៧៥[១៣] ។*

*ពេលដែលចូលនិវត្តន៍ អ្នកស្រីទៅរស់នៅស្រុកប៉ុងឌីស្ហេរី (បុតុច្ចេរិ) ប្រទេសឥណ្ឌា ក្នុងអាស្រមស្រីអៅរ៉ូប៊ិណ្ដូ (គ្រីអរវិន្ទ) ដើម្បីសំណាក់ធម៌រហូតដល់រលត់ជីវិតក្នុងឆ្នាំ ១៩៦៨ ។*

## អ្នកស្រី ការប៉ឺឡែស និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

*នៅថ្ងៃទី ១៣ សីហា ១៩២៦ ព្រះមហាក្សត្រព្រះចៅក្រុងកម្ពុជាធិបតី ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ បានសម្ពោធ «រាជបណ្ណាល័យ» ភ្នំពេញ ដែលមានអ្នកស្រី ការប៉ឺឡែស ជាស្ថាបនិក ហើយអ្នកស្រីបានទទួលមុខនាទីជាអភិរក្សលើកដំបូងបង្អស់[១៤] ។ រាជបណ្ណាល័យកម្ពុជាបានទទួលថែរក្សាជាទូទៅនូវអក្សរសាស្ត្រប្រទេសកម្ពុជា គឺមានអក្សរសិល្ប៍ខ្មែរ អក្សរសិល្ប៍ពុទ្ធសាសនាជាភាសាបាលីឬបាលីសម្រាយជាភាសាខ្មែរ ដូចជា* **អដ្ឋកថា, ដីកា, យោជនា, គន្ថា** *ជាដើម ។ តាមព្រះរាជប្រកាសថ្ងៃ ១ កុម្ភៈ ១៩២៦ អ្នកស្រី ការប៉ឺឡែស បានទទួលតំណែងជាបុគ្គលិកនៅក្រោមអធិបតីភាពសម្តេចចៅហ្វាវាំងនៃប្រទេសកម្ពុជា[១៥] ។*

*ចាប់ពីពេលនោះមក អ្នកស្រី ការប៉ឺឡែស លែងនៅក្នុងរដ្ឋបាលសាលាបារាំងចុងបូព៌ាទៀតហើយ ។ អ្នកស្រីមានឋានៈត្រឹមតែជាសមាជិកឆ្លើយឆ្លងនៃសាលាបារាំងចុងបូព៌ាប៉ុណ្ណោះ[១៦] ។ អ្នកស្រីចាប់ផ្តើមកម្មវិធីបោះពុម្ពផ្សាយអត្ថបទពុទ្ធសាសនាទាំងឡាយ ព្រមទាំងអត្ថបទអក្សរសិល្ប៍ជាទូទៅនៅរាជបណ្ណាល័យ ។ នៅឆ្នាំ ១៩២៦ ដដែលនេះ ទស្សនាវដ្តី* **កម្ពុជសុរិយា** *ក៏បានចាប់បដិសន្ធិឡើងដែរក្រោមការណែនាំរបស់អ្នកស្រីអគ្គបណ្ណរក្សរាជបណ្ណាល័យ[១៧] ។ នៅឆ្នាំ ១៩២៩ អ្នកស្រីបានធ្វើបេសកកម្មនៅខេត្តកូសាំងស៊ីន (កម្ពុជាក្រោម) ឃើញមានខ្មែរនិងវត្តអារាមជាច្រើន ហើយបានធ្វើទស្សនកិច្ចបន្ថែមនៅប្រទេសលាវទៀត បានឃើញវត្តអារាមនានាព្រមទាំងពុទ្ធមាមកជនទាំងឡាយ ។ ដូចនេះហើយ អ្នកស្រីក៏បានស្នើទៅអាជ្ញាធរមានសមត្ថកិច្ចសូមបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។ នាថ្ងៃ ២៥ មករា ឆ្នាំ ១៩៣០ មន្ទីរពុទ្ធសាសនបណ្ឌិត្យបានចាប់បដិសន្ធិឡើងនៅកម្ពុជា និង ១ ទៀតនៅប្រទេសលាវ ហើយដែលមានអ្នកស្រី ការប៉ឺឡែស ជាអគ្គលេខាធិការិនីនៃស្ថាប័នទាំង ២ ប្រទេសនេះ[១៨] ។ ពុទ្ធសាសនបណ្ឌិត្យមានតួនាទីធំបំផុត គឺ ការសិក្សាស្រាវជ្រាវពីព្រះពុទ្ធសាសនាដោយសង្កត់ជាមូលដ្ឋានធំ គឺ អត្ថបទ, គម្ពីរដីកានានាដែលជាប់ទាក់ទងនឹងពុទ្ធសាសនា ។ ដូចនេះ ស្ថាប័ននេះត្រូវបោះពុម្ពផ្សាយអត្ថបទនានាដែលមានទំនាក់ទំនងនឹងពុទ្ធសាសនា ហើយម្យ៉ាងទៀត ត្រូវរក្សាគម្ពីរដីកា, អដ្ឋកថានានា ឲ្យគង់វង្សទុកជាសម្បត្តិវប្បធម៌ប្រទេសកម្ពុជា[១៩] ។ «ក្រុមជំនុំព្រះត្រៃបិដក» បានបង្កើតឡើងនាខែធ្នូ ១៩២៩ ហើយព្រះត្រៃបិដកភាគទី ១ បានបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យក្រោមការដឹកនាំរបស់អ្នកស្រី ការប៉ឺឡែស នៅឆ្នាំ ១៩៣១[២០] ។*

*ចំណែកឯ «ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ» វិញ មានកំណើតឡើងនៅក្នុងឆ្នាំ ១៩៣៤ ដែលបាន*

បោះពុម្ពជាពិសេសនូវសៀវភៅ **ព្រះរាជពិធីទ្វាទសមាស** មានទាំងអស់ ៣ ភាគ[២១], **ប្រជុំរឿងព្រេងខ្មែរ** មាន ៩ ភាគ, **របាំប្រជាប្រិយខ្មែរ**, **ល្បែងប្រជាប្រិយខ្មែរ**, **លំនាំសង្ខេបនៃភ្លេងខ្មែរ** ។ល។ ក្រោមអធិបតីភាពអ្នកស្រី ការប៉ឺឡែស, ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយលើកទី ១ នូវ **វចនានុក្រមខ្មែរ** ភាគទី ១ នៅឆ្នាំ ១៩៣៨ និងភាគទី ២ នៅឆ្នាំ ១៩៤៣[២២] ។

ក្រៅពីសៀវភៅធម៌ពុទ្ធសាសនា, ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពអត្ថបទអក្សរសិល្ប៍ខ្មែរនានា គឺមានរឿងល្បែង ដូចជា **រឿងមរណមាតា**, **រឿងភាតី**, **រឿងទិព្វសង្វារ**, **រឿងសព្វសិទ្ធិ**, **រឿងព្រះជិនវង្ស**, **រឿងព្រះសុធន**, **រឿងហង្សយន្ត**, **រឿងពុទ្ធិសែន**, **រឿងស័ង្ខសិល្ប៍ជ័យ**, **រឿងខ្យងស័ង្ខ**, **រឿងសុបិនកុមារ**, **រឿងស្រទបចេក** ។ល។ ជាពិសេសទៅទៀត ដោយអ្នកស្រី ការប៉ឺឡែស យកចិត្តទុកដាក់ក្នុងការស្រាវជ្រាវផ្ទាល់ អ្នកស្រីបានឲ្យពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយរឿង **រាមកេរ្តិ៍** លើកទី ១ នៅឆ្នាំ ១៩៣៧ ពីខ្សែ ១ ដល់ខ្សែ ១០ ហើយពីខ្សែ ៧៥ ដល់ខ្សែ ៨០ ។ នៅខ្សែ ១ អ្នកស្រី ការប៉ឺឡែស បានធ្វើសេចក្តីផ្តើម ហើយនៅដើមខ្សែនីមួយៗ អ្នកស្រីក៏បានធ្វើសេចក្តីសង្ខេបជាភាសាបារាំងថែមទៀត[២៣] ។

ក្រៅពីគម្ពីរដីកាពុទ្ធសាសនា និងអក្សរសិល្ប៍ទំនៀម អ្នកស្រីយកចិត្តទុកដាក់លើអក្សរសិល្ប៍ទំនើប ដោយអនុញ្ញាតឲ្យបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី **កម្ពុជសុរិយា** នូវរឿង **ទឹកទន្លេសាប** តែងដោយលោក គឹម-ហាក់ នៅឆ្នាំ ១៩៣៩[២៤], រឿង **បិសាចស្នេហា** និពន្ធដោយលោក ញ៉ុក-ថែម ក្នុងឆ្នាំ ១៩៤២[២៥], រឿង **កំពូលកំសត់**[២៦] និពន្ធដោយលោក ហាន់-យេង នាឆ្នាំ ១៩៤៤, រឿង **កំពូលស្នេហា**[២៧] និពន្ធដោយលោក ហេង-យ៉ាន់ នាឆ្នាំ ១៩៤៦ ។

អ្នកស្រីមិនគ្រាន់តែធ្វើការស្រាវជ្រាវទៅលើអក្សរសិល្ប៍សំណេរប៉ុណ្ណោះទេ អ្នកស្រីក៏បានយកចិត្តទុកដាក់ទៅលើអក្សរសិល្ប៍សម្តីផងដែរ ។ ដោយឮសំណូរល្បីល្បាញនៃថ្វីមាត់តាកិរម្យឌ៉ុយ[២៨], អ្នកស្រី ការប៉ឺឡែស ក៏បានអញ្ជើញកវីប្រជាករនេះ មកច្រៀងសាដៀវនៅពុទ្ធសាសនបណ្ឌិត្យ ហើយបានឲ្យសហការីអ្នកស្រី គឺមានបណ្ឌិត ចាប់-ពិន, ប៊ូ-ប៉ូ, ជា-យូរ កត់ត្រាទុកនូវចម្រៀងទាំងអស់របស់កិរម្យឌ៉ុយ ហើយយកមកបោះពុម្ពជាកូនសៀវភៅតូចៗ[២៩] រក្សាទុកជាឯកសារឲ្យជនានុជនក្រោយសិក្សា នាទសវត្សរ៍ ១៩៣០ ហើយអ្នកស្រីបានជូនរង្វាន់ដល់តាឌ៉ុយ នូវប្រាក់ ១ រៀលជំនាន់នោះ[៣០] ។

ទាំងនេះបានសេចក្តីថា ជនជាតិបារាំងសែសមិនសុទ្ធតែជាអ្នកអាណានិគមនិយមទាំងអស់ទេ គឺមានជនបារាំងសែសខ្លះ ស្រឡាញ់វប្បធម៌អរិយធម៌ខ្មែរ ហើយចង់រក្សាឲ្យគង់វង្សជាអង្វែងតទៅ ទុកជាសម្បត្តិមនុស្សជាតិ[៣១] ។

ដោយលោក ហ្សក សេដែស នាយកសាលាបារាំងចុងបូព៌ា ធ្វើការស្រាវជ្រាវផ្ទាល់លើសិលាចារឹកខ្មែរ អ្នកស្រីបានឲ្យពុទ្ធសាសនបណ្ឌិត្យបោះពុម្ព **សិលាចារឹកនគរវត្ត** នៅឆ្នាំ ១៩៤១[៣២] ។

ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយជាភាសាបាលី ជាភាសាខ្មែរ និងភាសាបារាំង មានចំនួនទាំងអស់ ២៨១ ចំណងជើង ហើយបូករួមបន្ថែម **ព្រះត្រៃបិដក** ១១០ ភាគទៀត[៣៣] ៕

## កំណត់អត្ថន័យ

**(១)** សូមអាន CHERCHEURS D'ASIE [អ្នកស្រាវជ្រាវនៅអាស៊ីទ្វីប] ក្នុង *Répertoire bibliographique des membres scientifiques de l'École française d'Extrême-Orient 1898-2002* [**លីបិក្រមសមាជិកខឡាសាស្ត្រនៃសាលាបារាំងសែសនៅចុងបូព៌ាប្រទេស គ.ស. ១៨៩៨-២០០២**] ក្រុងប៉ារីស សាលាបារាំងចុងបូព៌ា គ.ស. ២០០២ ទំព័រទី ១២៨-១២៩ ។ សូមមើលវិបសាយរបស់សាលាបារាំងចុងបូព៌ា (http://www.efeo.fr) ។

**(២)** S. Karpelès [ស. ការប៉ឺឡែស] « Lokeçvaraçataka ou Cent strophes en l'honneur du Seigneur du Monde par Vajradatta » «[លោកេស្វរសតកៈ ឬ ១០០ បទ ជាកិត្តិយសដល់អាទិទេពពិភពលោក ដោយវជ្រទត្ត]» ក្នុង *Journal Asiatique* [**សារព័ត៌មានអាស៊ី**] លេខ ១៤ ទំព័រទី ៣៥៧-៤៦៥ ។

**(៣)** សូមអាន ហ្សង់ ហ្វីល្លីយ៉ូហ្សាត់ (Jean Filliozat) « Suzanne Karpelès » «[ស៊ុយហ្សាន ការប៉ឺឡែស]» ក្នុង *BEFEO* [**ព្រឹត្តិបត្រសាលាបារាំងសែសនៅចុងបូព៌ាប្រទេស**] គ.ស. ១៩៦៩ លេខ ៥៦ ទំព័រទី ១-៣ ។

**(៤)** សូមអាន Langues O' (1795-1995) [វិជ្ជាស្ថានបូព៌ាភាសា (គ.ស. ១៧៩៥-១៩៩៥)] *Deux siècles d'histoire de l'École des langues orientales* [**ប្រវត្តិសាស្ត្រសាលាភាសាបូព៌ា រយៈពេល ២ សតវត្សរ៍**] ប៉ារីស ការបោះពុម្ពហេរវ៉ាស គ.ស. ១៩៩៥ ទំព័រទី ៤៥៥ ។

**(៥)** សព្វថ្ងៃនេះ «សាលាបារាំងសែសនៅចុងបូព៌ាប្រទេស» ឬ «សាលាបារាំងចុងបូព៌ា» មានឈ្មោះជាភាសាខ្មែរថា «វិជ្ជាស្ថានបារាំងចុងបូព៌ាប្រទេស» ។

**(៦)** សូមអាន ស. ការប៉ឺឡែស « Un épisode du Rāmāyaṇa siamois » «[រឿងរាមកេរ្តិ៍សៀម ១ សង្កាត់]» ក្នុង *Études asiatiques* [**សិក្សាអាស៊ី**] លេខ ២ គ.ស. ១៩២៥ ទំព័រទី ៣១៥-៣៤២ ។

**(៧)** ស. ការប៉ឺឡែស « Six contes pālis tirés de la Dhammapadatthakathā » «[រឿងព្រេងបាលីប្រាំមួយចេញពី **ធម្មបទដ្ឋកថា**]» ក្នុង *Revue Indochinoise* [**ទស្សនាវដ្ដីឥណ្ឌូចិន**] គ.ស. ១៩២៤ លេខ ១-២ ទ. ១-៣០, លេខ ៣-៤ ទ. ២០៥-២៣៤, លេខ ៥-៦ ទ. ៣២៣-៣៥០, លេខ ៧-៨ ទ. ១១-៤៤ ។

**(៨)** សូមអាន លោក ហ្សង់ ហ្វីល្លីយ៉ូហ្សាត់ ដដែល ទំព័រទី ២ ។

**(៩)** «អ្នកស្រី ស៊ុយហ្សាន ការប៉ឺឡែស បានរងអំពើអយុត្តិធម៌នៃច្បាប់រដ្ឋាភិបាលវីស៊ីដែលប្រឆាំងអម្បូរសេមិត (ស៊្វីហ្វ) ហើយត្រូវគេបង្ខំឲ្យចូលនិវត្តន៍ដោយបញ្ញត្តិក្នុងឆ្នាំ ១៩៤១ ។ មាត្រាទណ្ឌនេះ ទុកជាមោឃៈក្រោយការរំដោះ ។» សូមមើល CHERCHEURS D'ASIE [អ្នកស្រាវជ្រាវនៅអាស៊ីទ្វីប] ដដែល ទំព័រទី ១២៩ ។

**(១០)** «ចាប់ពីខែសីហា ឆ្នាំ ១៩៤១ លោក ពីយែរ ឌុយប៉ុង បានមកស្នាក់ជាស្ថាពរនៅភ្នំពេញ ព្រោះបានកាន់តំណែងដែលបែរជាទំនេរ នៃអគ្គលេខាធិការរបស់ពុទ្ធសាសនបណ្ឌិត្យ ។ ពីរឆ្នាំក្រោយទៅ លោកក៏មានតំណែងបន្ថែមជាអភិរក្សប្រាសាទកម្ពុជា (លើកលែងតែប្រាសាទអង្គរ) ហើយចាប់ពីខែកុម្ភៈ ឆ្នាំ ១៩៤៤ ក៏មានតំណែងជាអភិរក្សសារមន្ទីរ អាល់ប៊ែរ សារ៉ូត៍ ថែមទៀត ។» តែងដោយលោក ហ្សក សេដែស ក្នុងអត្ថបទ « Nécrologie : Pierre Dupont (1908-1955) » «[ជីវប្រវត្តិអ្នកចែកឋាន៖ ពីយែរ ឌុយប៉ុង (គ.ស. ១៩០៨-១៩៥៥)]» ក្នុង *BEFEO* [**ព្រឹត្តិបត្រសាលាបារាំងសែសនៅចុងបូព៌ាប្រទេស**] លេខ ៤៩ ខ្សែ ២ គ.ស. ១៩៥៩ ទ. ៦៣៩ ។

**(១១)** ព្រះពុទ្ធឃោសាចារ្យ ជួន-ណាត មានតួនាទីជាសមាជិកឆ្លើយឆ្លងសាលាបារាំងចុងបូព៌ានៅឆ្នាំ ១៩៤៣ និងជាសមាជិកកិត្តិយសសាលាដដែលនេះនាឆ្នាំ ១៩៤៨ ។ សូមមើល CHERCHEURS D'ASIE [អ្នកស្រាវជ្រាវនៅអាស៊ីទ្វីប] ដដែល ទ. ៣០៦ ។

**(១២)** ព្រះសក្យវង្ស ហួត-តាត (ឬ ហ្វឹត-តាត) មានតួនាទីជាសមាជិកឆ្លើយឆ្លងសាលាបារាំងចុងបូព៌ានៅឆ្នាំ ១៩៤៣, ១៩៤៨, ១៩៥១, ១៩៥៤ ។ ដដែល ទ. ៣០៨ ។

**(១៣)** ដដែល ទ. ១២៩ ។

**(១៤)** សូមអាន លោក ហ្សង់ ហ្វីល្លីយ៉ូហ្សាត់ ដដែល ទំព័រទី ២ ។

**(១៥)** (កំណត់បណ្ណាធិការ ៖ ព្រះរាជប្រកាសនេះ បកប្រែពីភាសាបារាំង ព្រោះរកសេចក្តីដើមជាខេមរភាសាពុំឃើញ ។)

ក្រុងកម្ពុជាធិបតី
ព្រះរាជប្រកាស
យើង

ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ចមចក្រពង្សហរិរាជបរមិន្ទរភូវណៃ [ភូវន័យ] ក្រៃកែវហ្វាសុលាល័យ ព្រះចៅក្រុងកម្ពុជាធិបតីជាអម្ចាស់ជីវិតលើត្បូង

បានទ្រង់យល់ព្រះរាជប្រកាសពីថ្ងៃ ᧬ ៨ ឆ្នាំរកានពស័ក ត្រូវនឹងថ្ងៃទី ១១ ខែស៊ូយ៉េត [កក្កដា] ឆ្នាំ ១៨៩៧ ស្តីពីការគ្រប់គ្រងព្រះរាជអាណាចក្រ ។

បានទ្រង់យល់ព្រះរាជប្រកាសពីថ្ងៃ ᧡ ៨ ឆ្នាំម្សាញ់សប្តស័ក ត្រូវនឹងថ្ងៃទី ៣ ខែស៊ូយ៉េត [កក្កដា] ឆ្នាំ ១៩០៥ ស្តីពីនាទីរបស់កុង្សុីយ៍សេនាបតី ។

បានទ្រង់យល់ព្រះរាជប្រកាសពីថ្ងៃ ᧫ ៨ ឆ្នាំរកាត្រីស័ក ត្រូវនឹងថ្ងៃទី ១៥ ខែស៊ូយ៉េត [កក្កដា] ឆ្នាំ ១៩២១ ស្តីពីការបង្កើតព្រះរាជបណ្ណាល័យនៅក្រុងភ្នំពេញ ។

បានទ្រង់យល់ព្រះរាជប្រកាសពីថ្ងៃ ᧥ ៥ ឆ្នាំខាលអដ្ឋស័ក ត្រូវនឹងថ្ងៃទី ១៨ ខែម៉ារ្ស [មីនា] ឆ្នាំ ១៩២៦ ស្តីពីការរៀបចំព្រះរាជបណ្ណាល័យឡើងវិញ ជាពិសេសប្រការ ៤ ។

បានទ្រង់យល់កិច្ចសន្យាជួលម៉ាដឺមូអាហ្សែល [កញ្ញា] ការប៊ីឡែស ចុះថ្ងៃទី ១ ខែហ្វេវរីយេ [កុម្ភៈ] ឆ្នាំ ១៩២៦ ។

បានទ្រង់យល់ការយល់ព្រមរវាងយើងនិងលោកឡឺរ៉េស៊ីដង់ត៍ស៊ុប៉េរីយើរ ។

ដោយការស្នើសុំរបស់លោកឡឺរ៉េស៊ីដង់ត៍ស៊ុប៉េរីយើរដឺឡារេពូប្លិកបារាំងសែស [ឯកាធិបតីនៃសាធារណរដ្ឋបារាំងសែស] ក្នុងក្រុងកម្ពុជា ។

ត្រាស់បង្គាប់ជាស្រេច ៖

ប្រការ ១ - នាងស្រ្តី ស៊ុយហ្សាន ការប៊ីឡែស សមាជិកស្តីទីនៃសាលាបារាំងសែសនៅចុងបូព៌ាប្រទេសនៅឆ្នាំ ១៩២៣ និង ១៩២៤ មានសញ្ញាប័ត្រសាលាសិក្សាអនុវត្តជាន់ខ្ពស់ (ស៊របោន) និងមានសញ្ញាប័ត្រសាលាភាសារស់ខាងកើត បានឡើងជាអភិរក្សព្រះរាជបណ្ណាល័យ ។

ប្រការ ២ - យើងអនុញ្ញាតសម្តេចចៅហ្វាវាំងឲ្យធ្វើកិច្ចសន្យាក្នុងព្រះបរមនាមាភិធេយ្យយើង ដែលកំណត់ល័ក្ខខ័ណ្ឌជួលនាងស្រ្តី ស៊ុយហ្សាន ការប៊ីឡែស ។

ព្រះរាជប្រកាសធ្វើក្នុងព្រះបរមរាជវាំង ចតុរមុខ ក្រុងភ្នំពេញនៅថ្ងៃ ᧥ ៥ ចុល្លសករាជ ១២៨៧ ឆ្នាំខាលអដ្ឋស័ក ត្រូវគ្នានឹងថ្ងៃទី ១៨ ខែម៉ារ្ស [មីនា] ឆ្នាំ ១៩២៦ ។

ឡាយព្រះហស្តលេខា ៖ ស៊ីសុវត្ថិ ។

បានឃើញ និងឲ្យអំណាចចាត់ការតាមប្រកាសអារេតេ [អនុក្រឹត្យ] លេខ ៩៣៦ ចុះថ្ងៃ ២០ ខែ អាវរីល [មេសា] ឆ្នាំ ១៩២៦ ។

ឡឺរ៉េស៊ីដង់ត៍ស៊ុប៉េរីយើរ

បូដូវ៉ាំង ។

**(១៦)** សូមអានលិខិតលេខ ៤២១, អ្នកស្រី ការប៊ីឡែស ចំពោះនាយកសាលាបារាំងចុងបូព៌ា ចុះថ្ងៃទី ១២ ខែសីហា ១៩២៧ (បកប្រែពីភាសាបារាំងសែស) ៖

ពីអភិរក្សនៃព្រះរាជបណ្ណាល័យជូនចំពោះលោកចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ។ ក្រុងហាណូយ ។

ជូនជម្រាបលោក ។

នាងខ្ញុំទើបនឹងទទួលកំណត់របស់លោក ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ១៩២៧ ដែលប្រាប់នាងខ្ញុំថា នាងខ្ញុំជាសមាជិកឆ្លើយឆ្លងរបស់សាលាលោក តាំងពីជិត ១ ឆ្នាំមកហើយ ។ រឿងនេះ នាងខ្ញុំពុំបានដឹងទាល់តែសោះ ។

ដូច្នេះ នាងខ្ញុំសូមលោកមេត្តាប្រាប់នាងខ្ញុំអំពីអ្វីដែលសាលាបារាំងសែសនៅចុងបូព៌ាប្រទេស សុំឲ្យសមាជិកឆ្លើយឆ្លងធ្វើ ។

ដោយសារនាងខ្ញុំជាអតីតសមាជិកនៃសាលាបារាំងសែសនៅចុងបូព៌ាប្រទេស និងជាសមាជិកឆ្លើយឆ្លង នាងខ្ញុំសូមជម្រាបលោកថា លោកអាចពឹងការចូលដៃអស់ពីដួងចិត្តរបស់នាងខ្ញុំ ។

សេចក្តីគួរពុំគួរ សូមលោកចាងហ្វាងមេត្តាអភ័យទោស ។

ហត្ថលេខា ៖ ស៊ុយហ្សាន ការប៉ុឡែស ។

**(១៧)** សូមអាន លោក ហ្សាក់ ណេពត (Jacques Népote) « Introduction à une histoire de la presse au Cambodge » «[ការរៀបរាប់ដំបូងអំពីប្រវត្តិសារព័ត៌មាននៅប្រទេសកម្ពុជា]» ក្នុង *Présence indochinoise* [**វត្តមានឥណ្ឌូចិន**] លេខ ២ ប៉ារីស ខែសីហា ឆ្នាំ ១៩៧៩ ទ. ៩៦-១២៩ ។

**(១៨)** សូមអានអនុក្រឹត្យ ២ ដែលចុះហត្ថលេខាដោយលោក ពីយែរ ប៉ាស្គីយេ ៖

**១)** ឡឺគូវែរណើរ យេណេរ៉ាល ដឺឡាំងដូស៊ីន [អគ្គទេសាភិបាលនៃឥណ្ឌូចិន]

កុំម៉ង់ឌឺរ៍ ដឺឡាឡេស៊ីយ៉ុងដូណើរ [មន្ត្រីជាន់ខ្ពស់ពាក់មេដាយឡេហ្ស៊ីយ៉ុងដូណើរ] ។

បានឃើញប្រកាសដេក្រេ [ក្រឹត្យ] ចុះថ្ងៃ ២០ ខែអុកតូប [តុលា] ឆ្នាំ ១៩១១ សំរេចអំណាចលោកគូវែរណើរយេណេរ៉ាល [អគ្គទេសាភិបាល] នឹង របៀបរៀបចំខាងឃ្លាំងប្រាក់ នឹងរាជការត្រួតត្រាគ្រប់គ្រងប្រទេសឥណ្ឌូស៊ីន [ឥណ្ឌូចិន] ។

បានឃើញប្រកាសអារេតេ [អនុក្រឹត្យ] ចុះថ្ងៃ ២៥ ខែយ៉ាំងវីយេរ [មករា] ឆ្នាំ ១៩៣០ ដែលតាំងបង្កើតមន្ទីរស្រុកអាយមួយ សំរាប់សិក្សាព្រះពុទ្ធសាសនាប៉ែកខាងហីនយាន នៅក្រុងភ្នំពេញ ។

បានឃើញប្រកាសអារេតេ [អនុក្រឹត្យ] ចុះថ្ងៃ ១២ ខែម៉េ [ឧសភា] ឆ្នាំ ១៩៣០ ស្តីពីការតែងតាំងអ្នកស្រី ស៊ុយហ្សាន ការប៉ុឡែស ជាលេខាធិការរបស់មន្ទីរស្រុកអាយសំរាប់សិក្សាព្រះពុទ្ធសាសនាប៉ែកខាងហីនយាន ។

បានឃើញប្រកាសអារេតេ [អនុក្រឹត្យ] ចុះថ្ងៃ ១៣ ខែម៉េ [ឧសភា] ឆ្នាំ ១៩៣៣ ដែលកែប្រែប្រកាសអារេតេ [អនុក្រឹត្យ] ចុះថ្ងៃ ២៥ ខែយ៉ាំងវីយេរ [មករា] ឆ្នាំ ១៩៣០ ។

កំណត់ ៖

ប្រការ ១ ៖ ប្រការ ១ នៃប្រកាសអារេតេ [អនុក្រឹត្យ] ចុះថ្ងៃ ១៣ ខែម៉េ [ឧសភា] ឆ្នាំ ១៩៣០ ដែលចែងមកនេះ ត្រូវបានកែប្រែដូចតទៅនេះ ៖

ប្រការ ១ - អ្នកស្រី ស៊ុយហ្សាន ការប៉ុឡែស អភិរក្សព្រះរាជបណ្ណាល័យកម្ពុជា ត្រូវហៅឲ្យមានមុខងារជាអគ្គលេខាធិការនៃមន្ទីរស្រុកអាយសំរាប់សិក្សាព្រះពុទ្ធសាសនាប៉ែកខាងហីនយាន ។

ប្រការ ២ - អគ្គលេខាធិការនៃរាជការគូវែរណើម៉ង់យេណេរ៉ាល ដឺឡាំងដូស៊ីន [អគ្គរដ្ឋាភិបាលនៃឥណ្ឌូចិន] និងរ៉េស៊ីដង់ស៊ុប៉េរីយើរ (ឯកាធិបតី) នៅនគរកម្ពុជា ត្រូវទទួលសំរេចចាត់ការតាមប្រកាសអារេតេ [អនុក្រឹត្យ] នេះដោយរៀងខ្លួន ។

ស្រុកហាណូយ ថ្ងៃ ៦ ខែអុកតូប [តុលា] ឆ្នាំ ១៩៣៣ ។

ស៊ីញេ [ហត្ថលេខា] ៖ ព. ប៉ាស្គីយេ ។

**២)** ឡឺគូវែរណើរ យេណេរ៉ាល ដឺឡាំងដូស៊ីន [អគ្គទេសាភិបាលនៃឥណ្ឌូចិន]

កុំម៉ង់ឌឺរ៍ ដឺឡាឡេស៊ីយ៉ុងដូណើរ [មន្ត្រីជាន់ខ្ពស់ពាក់មេដាយឡេហ្ស៊ីយ៉ុងដូណើរ] ។

បានឃើញប្រកាសដេក្រេ [ក្រឹត្យ] ចុះថ្ងៃ ២០ ខែអុកតូប [តុលា] ឆ្នាំ ១៩១១ សំរេចអំណាចលោកគូវែរណើរយេណេរ៉ាល [អគ្គទេសាភិបាល] នឹង របៀបរៀបចំខាងឃ្លាំងប្រាក់ នឹងរាជការត្រួតត្រាគ្រប់គ្រងប្រទេសឥណ្ឌូស៊ីន [ឥណ្ឌូចិន] ។

បានឃើញប្រកាសអារេតេ [អនុក្រឹត្យ] ចុះថ្ងៃ ២៥ ខែយ៉ាំងវីយេរ [មករា] ឆ្នាំ ១៩៣០ ដែលតាំងបង្កើតមន្ទីរស្រុកអាយ

មួយ សម្រាប់សិក្សាព្រះពុទ្ធសាសនាប៉ែកខាងហីនយាន នៅក្រុងភ្នំពេញ ។

បានឃើញប្រកាសអារេតេ [អនុក្រឹត្យ] ចុះថ្ងៃ ១៣ ខែម៉ៃ [ខែឧសភា] ឆ្នាំ ១៩៣៣ ដែលកែប្រែប្រកាសអារេតេ [អនុក្រឹត្យ] ចុះថ្ងៃ ២៥ ខែយ៉ាំងវីយេរ [មករា] ឆ្នាំ ១៩៣០ ។

កំណត់ ៖

ប្រការ ១ - លោក ស៊ីលវែស្ត្រ រ៉េស៊ីដង់ស៊ុប៉េរីយើរ (ឯកាធិបតី) នៅក្រុងកម្ពុជា ឡើងតំណែងជាអធិបតីកិត្តិយសនៃមន្ទីរស្រុកអាយសំរាប់សិក្សាព្រះពុទ្ធសាសនា ។

ប្រការ ២ - សម្តេចក្រុមព្រះវរចក្ររណរិទ្ធី [រណឫទ្ធិ] នរោត្តម សុទ្ធារស [សុធារស] និងព្រះអង្គម្ចាស់ ភិតសរ៉ាត (វជ្ររត្ន) [ព្រះអង្គម្ចាស់ ពេជ្ររាជ] ត្រូវចាត់តាំងដើម្បីទទួលអធិបតីភាពនៃសាខាក្រុងភ្នំពេញ និងក្រុងវៀងច័ន្ទន៍របស់មន្ទីរស្រុកអាយសម្រាប់សិក្សាព្រះពុទ្ធសាសនា ។

ស្រុកព្រៃនគរ ថ្ងៃ ៣១ ខែស៊ូយ៉េត [កក្កដា] ឆ្នាំ ១៩៣៣ ។

ស៊ីញ្ញេ [ហត្ថលេខា] ៖ ព. ប៉ាស្គីយេ ។

**(១៩)** ពុទ្ធសាសនបណ្ឌិត្យបានរក្សាសាស្ត្រា, គម្ពីរដីកានានារហូតមកដល់ឆ្នាំ ១៩៧២, តាមតួលេខបញ្ជី ពីលេខ ១ ដល់លេខ ១៦៤៧ ដោយបូករួមទាំងអស់ គឺមាន ១៣.៤៧១ គម្ពីរ ។

**(២០)** ក្រុមជំនុំព្រះត្រៃបិដកបានចាប់បកប្រែពីអត្ថបទបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩២៩ ហើយបានបកប្រែចប់នៅឆ្នាំ ១៩៦៨ ពោលគឺអស់រយៈពេល ៣៩ ឆ្នាំ ។ ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយទាំងអស់ មាន ១១០ ភាគ ហើយភាគទី ១១០ ចេញផ្សាយនៅឆ្នាំ ១៩៦៨ ។ ក្នុងភាគនីមួយៗ មានចំនួនទំព័រជាមធ្យមរវាង ៥០០ ឬ ៦០០ ទំព័រជា ២ ភាសា គឺ ភាសាបាលីម្ខាង និងភាសាខ្មែរម្ខាងទៀត ។

**(២១)** ក្រុមជំនុំទំនៀមទម្លាប់ជំនាន់នោះ គឺមាន ៖ លោក ហ្ស. កាំប៊ីហ្វ័រត៍, ព. ឌុយប៉ុងត៍, ញ៉ុក-ថែម, យឿន-ចឹម ព្រមទាំង

-សម្តេចវរចក្រ រណរឹទ្ធិ ន. សុធារស, ព្រះអង្គម្ចាស់ក្សត្រីមាលិកា ។

-សម្តេចឥសីភទ្ទាធិបតី ម៉ាំង ចាងហ្វាងក្រុមបារគូ, ព្រះព្រហ្មជ័យ កែវ-ម៉ក់ អធិបតីក្រុមរក្សាព្រះខ័ននៅស្រុកបារាយណ៍ (កំពង់ធំ) ។

-ឧកញ៉ារាជវរានុកូល ឃិន បាឡាត់ទូលឆ្លងក្រុមជំរឺព្រះរាជទ្រព្យ និងឃុនអក្ខរាពិណពាទ្យ ស៊ូ-អ៊ីន ក្រុមភ្លេងព្រះរាជទ្រព្យ ។

ទាំងនេះក្រោមក្រុមនិពន្ធ មាន ៖

-ឧកញ៉ាទេពពិទូរ ក្រសេម បណ្ឌិតទី ១ នៅពុទ្ធសាសនបណ្ឌិត្យ ជាអ្នកតែងរៀបរៀងសៀវភៅ ។

-អ្នកស្រី អឺ. ប៉ូរ៉េ-ម៉ាស្ប៉េរ៉ូ បានពិនិត្យ,

-នាងកញ្ញា ស៊ីម-វ៉ុនស៊ី, បណ្ណារក្សនៅពុទ្ធសាសនបណ្ឌិត្យ ជាអ្នកប្រែចេញជាភាសាបារាំង ។

**(២២)** ក្រុមជំនុំវចនានុក្រម មានដើមកំណើតឡើងនៅឆ្នាំ ១៩១៥ ៖

«អធិបតីនិងក្រុមជំនុំ

«ដែលតាំងដោយព្រះរាជប្រកាសលេខ ៦៧ ចុះថ្ងៃទី ៤ ខែសេបតមប្រ៏ [ខែកញ្ញា] ឆ្នាំ ១៩១៥ និងព្រះរាជប្រកាសតាមលំដាប់មុនក្រោយឲ្យបង្កើតវចនានុក្រមខ្មែរ ។ ...» សូមអាន «សេចក្តីប្រារព្ធរបស់ក្រុមជំនុំ» **វចនានុក្រមខ្មែរ**, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥១១ គ.ស. ១៩៦៧ ទំព័រ ត-ទ ។

**(២៣)** សូមអាន **រឿងរាមកេរ្តិ៍** បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ។

**(២៤)** គឹម-ហាក់ «ទឹកទន្លេសាប» **កម្ពុជសុរិយា** គ.ស. ១៩៣៩, ១១, ១-៣: ៧-៣២; ១១, ៧-៩: ១៧-៣៤; ១១, ១០-១២: ១៧-៤២ ។ អ្នកស្រី ការប៉ឺឡែស អនុញ្ញាតឲ្យ «ការផ្សាយព្រះរាជបណ្ណាល័យកម្ពុជា» បោះពុម្ពប្រលោមលោកនិពន្ធដោយលោក គឹម-ហាក់ ឡើងវិញ ជាសៀវភៅមួយក្បាលចប់នៅឆ្នាំ ១៩៤១ ។

**(២៥)** ញ៉ុក-ថែម «បិសាចស្នេហា» **កម្ពុជសុរិយា** គ.ស. ១៩៤២, ១៤, ១៥-១៦: ៨-២៥; ១៤, ១៨-១៩: ២០-៤១ ។

**(២៦)** ហាន់-យេង «កំពូលកំសត់» **កម្ពុជសុរិយា** គ.ស. ១៩៤៤, លេខ ១-១២ ។

**(២៧)** ហេង-យ៉ាន់ «កំពូលស្នេហា» **កម្ពុជសុរិយា** គ.ស. ១៩៤៦, លេខ ១-១១ ។

**(២៨)** សូមអាន លី-ធាមតេង **វណ្ណកនិពន្ធខ្មែរ, ភិរម្យ-ង៉ុយ** ភ្នំពេញ, សេង-ងួនហ្វួត, គ.ស. ១៩៦៦ ។ សូមអាន សាន-សារិន (San Sarin) « Phirum Ngoy, poète khmer d'après Ly Theam Téng » «[ភិរម្យ ង៉ុយ ជាកវីខ្មែរតាមប្រសាសន៍របស់លោក លី-ធាមតេង]» ក្នុង *Cambodge nouveau* **កំបូជាថ្មីឆ្លងថ្មី** ([**កម្ពុជាថ្មី**]) លេខ ១៩ គ.ស. ១៩៧១ ទ. ២៥-៣៥; ឃីង-ហុកឌី និង ហ្សាក់លីន-ឃីង (Khing Hoc Dy et Jacqueline Khing) **បណ្ដាំក្រមង៉ុយ** *Les Recommandations de Kram Ngoy* មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរ ក្រុងប៉ារីស គ.ស. ១៩៨១; *Mon-Khmer Studies* [**សិក្សាមន-ខ្មែរ**] លេខ ៧ គ.ស. ១៩៧៨ ទ. ១៤១-១៨២ ។

**(២៩)** សូមអាន **ច្បាប់ក្រមង៉ុយ, ច្បាប់ល្បើកថ្មី, ច្បាប់កេរកាល, សេចក្ដីទំលឹកដាស់តឿន, ពាក្យកាព្យប្រដៅជនប្រុសស្រី**, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, គ.ស. ១៩៧៣ (បោះពុម្ពលើកទី ៧) ។

**(៣០)** «អ្នកស្រីនាយក (ស៊ុយហ្សាន ការប៉ឺឡែស) បានឲ្យអ្នកប្រាជ្ញនៅវិជ្ជាឋានកត់ត្រាសំដី ចម្រៀង កំណាព្យតាង៉ុយទាំងអស់ពេលដែលលោកច្រៀងរង្វើល។ ។ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពកំណាព្យតាង៉ុយជាកូនសៀវភៅបួន ។ អ្នកស្រីនាយកបានឲ្យកម្រៃជាប្រាក់ ១ រៀលជំនាន់នោះ ។ ប្រាក់ ១ រៀលតិចមែនពិត តែអំណោយនេះសឹងតែទុកជាកិច្ចប្រវត្តិសាស្ត្របង្ហាញឲ្យឃើញថា បារាំងទាំងអស់មិនមែនសុទ្ធតែជាអ្នកអាណានិគមនិយមមកជិះជាន់ខ្មែរ គឺមានអ្នកប្រាជ្ញខ្លះ។ ស្រឡាញ់រាប់អានវប្បធម៌ អរិយធម៌ ចង់រក្សាទុកជាស្នាដៃមនុស្សជាតិ ។» ដោយលោក កេង-វ៉ាន់សាក់ (Keng Vannsak) « Réflexions sur la littérature khmère » «[ការជញ្ជឹងគិតអំពីអក្សរសិល្ប៍ខ្មែរ]» ក្នុង *La Revue française, présente le Cambodge* [**ទស្សនាវដ្ដីបារាំងសែសនាំឱ្យស្គាល់ប្រទេសកម្ពុជា**] លេខ ២០៦ ខែមករា គ.ស. ១៩៦៨, ទ. ៣៤ ។

**(៣១)** សូមអាន ឃីង-ហុកឌី និង ហ្សាក់លីន-ឃីង (Khing Hoc Dy et Jacqueline Khing) **បណ្ដាំក្រមង៉ុយ** *Les Recommandations de Kram Ngoy* មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរ ក្រុងប៉ារីស ឆ្នាំ ១៩៨១ ។

**(៣២)** សូមអានលិខិតលោក ហ្សក សេដែស ជូនចំពោះអ្នកស្រី ការប៉ឺឡែស ចុះថ្ងៃទី ១១ វិច្ឆិកា គ.ស. ១៩៤០ (បកប្រែពីភាសាបារាំងសែស)៖ «ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ១៩៤០ ។

«ជូនចំពោះអ្នកស្រី ស. ការប៉ឺឡែស អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ។

«មកដល់មិត្តជាទីស្រឡាញ់ ។

«ខ្ញុំសូមអរគុណអ្នក អំពីការបានផ្ញើរបចតដែលអ្នកយកទៅប្រើសម្រាប់តែងលំអអត្ថបទទិវានុប្រវត្តិរបស់អ្នកទៅខ្ញុំ ។

«ខ្ញុំក៏សូមអរគុណអ្នកអំពីឯកសារដែលទាក់ទងនឹងការសម្ដែងនៅថ្ងៃទី ៣ ខែវិច្ឆិកា ។

«ខ្ញុំអរណោស់ដោយបានដឹងថា សៀវភៅសិលាចារឹកនគរវត្តរបស់ខ្ញុំ អាចមានភ័ព្វទៅបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៤១ ។

«នៅឯកន្លែងខ្ញុំនោះ ជីវិតនៅតែបន្តទៅទៀត ។ យើងខ្ញុំនឹងចាប់ផ្ដើមធ្វើសន្និសីទតទៅទៀត ចាប់ពីថ្ងៃចន្ទក្រោយ ។ ប្រហែលអ្នកបានឃើញកម្មវិធីនេះក្នុងកាសែត ។

«តើអ្នកស្រីគិតទៅហាណូយក្នុងឆ្នាំនេះឬ? ។

«ដោយមេត្រី ។»

ហត្ថលេខា៖ ហ្ស. សេដែស ។

**(៣៣)** សូមអាន *Liste des ouvrages édités par l'Institut bouddhique* [**បញ្ជីសៀវភៅបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ**] ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៩ ៕